# គំនិត ក្រិន




គំនិត ក្រិន

បើនិយាយ អំពី សញ្ញាណ នៃ អត្តង្គត ត្រូវមាន ការប្រុងប្រយ័ត្ន ព្រោះ វា ហាក់ជា កត្តា នៃ ការរីកចំរើន ឬ ឱនភាព ផងដែរ។ ទោះយ៉ាងណាក្តី សញ្ញាណ នោះ មាន លក្ខណវិនិច្ឆ័យ របស់វា ច្បាស់លាស់ ដូចយ៉ាង ប្រជាជាតិមួយ, សង្គមមួយ, អ្នកនយោបាយមួយក្រុម វា ដើរមកដល់ ចំណុចមួយ ដែល លែងប្រែប្រួល គំនិត បានទៀត (scléroser) ព្រោះវា បង្ហាញ អសមត្ថភាព របស់ខ្លួន ដែលមិនអាចដកស្រង់ ពី ការពិសោធន៍ ដែលខ្លួន បានជួបប្រទះ ដើម្បី ប្តូរ អាចារៈ[1] របស់ខ្លួន ជា មេរៀន។ សព្វថ្ងៃ ជននិករ នយោបាយ គ្រប់ មជ្ឈដ្ឋាន ពួក គាត់ ស្ថិតនៅក្នុង ស្ថានភាព បែបនេះឯង គឺ ជួបនឹង ជីវិតជរាភូត[2] លែងដូរ ចរិតបាន នាំគ្នា ប្រកោងនឹង ទម្លាប់ចាស់ ឬ មនោគមវិជ្ជា ចំណាស់ ដោយ មិនរវល់នឹង មេរៀនប្រវត្តិសាស្ត្រ នោះឡើយ។ ជា ឧទាហរណ៍ : ពួក អ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ ពេលជួប ប្រទេះនឹង បញ្ហានយោបាយ នាំគ្នា ទៅបន់ ព្រះ, អារក្ស, អ្នកតា, សូមសុខ ហើយ ពេល សមាជិកខ្លួន ជាប់គុក នាំគ្នា ទៅ ចរចា ជាមួយ ពួក អ្នកបំពានច្បាប់ អោយជួយ រកយុត្តិធម៌ ដោយប្រើ រូបមន្ត សូត្រមន្តគាថា ឈ្មោះថា « វប្បធម៌

[1] អាចារៈ; (អកប្បកិរិយា)។

[2] ជីវិតជរាភូត; ជីវិតដែលជរាគ្របសង្កត់។

## គំនិត ក្រិន

សន្ទនា » ដែល ជា រូបមន្ត គ្មានបញ្ហា គ្រាន់តែជាការនិយាយ គ្នាប៉ប៉ាច់ប៉ប៉ោច តែ នាំគ្នាគិតថា ជា ឱសថសព្វគុណ អាច អោយជារោគ ឆ្កួតអំណាច, ឆ្កួតលុយ, ឆ្កួតកាមតណ្ហា និង ឆ្កួត ខ្លាចយួន។ តែ តាពិត វា ជា ថ្នាំ ប្រសូតិកា នូវ បញ្ហាក្រៃមុះហិម្មា ដល់ ជាតិខេមរា។ រីឯ ពួក អ្នកកាន់អំណាច វិញ តាំង ពី វ័យ ក្មេង ដល់ ចាស់ គ្មានកែគំនិត ឥតផលដល់ជាតិ គឺ បំរើយួន រហូត ទោះបី ខ្លួន ដឹងច្បាស់ ថា អំពើ ដែល ខ្លួន កំពុង ធ្វើ វា ជា មាតុភូមុឃាត ព្រោះតែ លង់លិច ក្នុងគំនិត ដឹងគុណយួនមួយ ជីវិត យកទឹកដីខ្មែរ ជា បំណុល រួច ដាក់ចូល ទៅក្នុង បញ្ជីឥណ ប្រតិទាន[3] ហើយ យកវា ទៅតំកល់ទុក នៅ ទីក្រុង ហាណូយ ជា ប័ណ្ណអនុញ្ញាត អោយ ប្រជាជនយួន មករស់នៅ តាមសេរី នៅ ស្រុកខ្មែរ។ មែនទែន, ពួក អ្នកប្រឆាំង និង ពួក អ្នកកាន់ អំណាចផ្តាច់ការ អនុវត្ត ប្រកោះគ្នា តាំងពីយូរយារ មកហើយ នូវ នយោបាយ ទុក ប្រជាពលរដ្ឋ ជា ប្រជាជន សំរាប់ តែ បោះ ឆ្នោត; យកត្រចៀកចុក សំរាប់ ស្តាប់រាស្ត្រ ត្អូញត្អែ ពី មហាទុក្ខ ប្រចាំជីវិត តែ មាន គំនិត ជា អ្នកបោកប្រាស់ ជា មនុស្ស លាមក នាំគ្នា ទាញយកចំណេញ ពី ទុព្វលភាព នៃ ប្រជាពលរដ្ឋ ក្ររហាម រស់សំរាប់តែមួយថ្ងៃ ក្នុងគំលាន។ ពួកហ្នោះ ក្រោយ ពី ការបោះឆ្នោតរួច នាំគ្នា ក្លែង លទ្ធផល ហើយ បូកបោះ ចែក ប្រយោជន៏គ្នា ប្រកបដោយ បការ ដើងកាង[4] ដែលជា ទម្លាប់

[3] បញ្ជីឥណប្រតិទាន; បញ្ជីថ្ងៃសងបំណុល ; échéancier។
[4] ប្រកបដោយ បការ ដើងកាង ; avec une méthode voyou។

## គំនិត ក្រិន

របស់ ពួក អ្នកដឹកនាំ ក្នុង សម័យ សក្តិភូមិ គឺថា អ្នកខ្សោយ ស៊ី ឆ្អឹង, អ្នកខ្លាំង ស៊ី សាច់ស្អុយ សល់ ពី យួន ព្រោះ ពួក អមនុស្ស ទាំងនោះ មាន ធម្មជាតិ ជា ត្មាត ស៊ី គម្រង់សត្វ។ តាំង ពី ឆ្នាំ ១៩៩៣ មក នាំគ្នា បំផ្លាញ កិច្ចព្រមព្រៀង សន្តិភាព ២៣ តុលា ដែល ជា ខែលដែក សំរាប់ ការពារនឹង ការឈ្លានពានយួន ហើយ នាំគ្នា បន្ត កំទិច ប្រជាជាតិខ្លួនឯង ដោយ យក ការ បោះឆ្នោត បញ្ឆោតរាស្ត្រ ថា ជា ដំណោះស្រាយ ថែរក្សាសន្តិភាព និង ការអភិវឌ្ឍន៏ ឬ ដើម្បី អនុវត្ត គោលការណ៏ ៥ចំណុច[5]។ ពាក្យ សន្យា ទាំងនោះ គេ ធ្លាប់ឮ ពីរ ទស្សវត្សរ៏ រួចមកហើយ ព្រោះ ពួក អ្នកស៊ីគម្រង់សត្វ ទាំងនោះ គាត់ និយាយ គ្រាន់តែ អោយឮ តែ គំនិត របស់គាត់ វា ក្រិន ដោយ អំណាចយួន ដែល វា បំពុល ពួកគាត់ អោយ រស់ ជា អ្នកក្បត់ជាតិ ដើម្បី ជួយ យួន អោយ ប្លន់ យក ទឹកដីកម្ពុជា។ គំនិតក្រិន នេះឯង ជា អនាគត របស់ ប្រជាជាតិ បើ ពលរដ្ឋខ្មែរ ម្នាក់ៗ នាំគ្នា បន្ត ដើរលើ ផ្លូវ ជា ឧន្នាគ៏ា[6] ដែលពួក អ្នកបោកប្រាស់ គេលើកវា សំ រាប់អោយដើរ ដូច្នេះ កុំនាំគ្នា ត្អូញត្អែ បន្តទៀត ក្រោយពេល បោះឆ្នោតរួច។ បើ ប្រជាពលរដ្ឋខ្មែរ មាន គំនិតក្រិន ដូច ពួក ត្មាត គឺ ជនយួន នោះឯង ជា អ្នក មាន គំនិតប្រាជ្ញា លួច ជាតិខ្មែរបាន៕

---

[5] គោលការណ៏ ៥ចំណុច របស់គណបក្សសង្គ្រោះជាតិ៖ ១. ពង្រឹងសិទ្ធិអំណាចប្រជាពលរដ្ឋ, ២. លើកកម្ពស់ជីវភាពប្រជាពលរដ្ឋ, ៣. សេវាសាធារណៈ, ៤. សន្តិសុខ, ៥. វិម្ឋការ។

[6] ឧន្នាគ៏ា; ផ្លូវទុក្ខ ; chemin du mal។